ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងមុខងារសាធារណៈ

# លិខិតថ្វាយព្រះពរ

## សូមក្រាបបង្គំទូលថ្វាយ

## សម្តេច ព្រះមហាក្សត្រី នរោត្តម មុនីនាថ សីហនុ

## ព្រះវររាជមាតាជាតិខ្មែរ ក្នុងសេរីភាព សេចក្តីថ្លៃថ្នូរ និង សុភមង្គល

**សម្តេចព្រះមហាក្សត្រីជាទីសក្ការៈ**

ក្នុងឱកាសដ៏មហានក្ខត្តឫក្ស មហាមង្គលនៃព្រះរាជពិធីបុណ្យចម្រើនព្រះជន្ម **សម្តេចព្រះមហាក្សត្រី** គម្រប់ ៨២ យាងចូល ៨៣ ព្រះវស្សា ទូលព្រះបង្គំខ្ញុំម្ចាស់ទាំងអស់គ្នា ជាថ្នាក់ដឹកនាំ មន្ត្រីរាជការ នៃក្រសួងមុខងារសាធារណៈ សូមលំអោនកាយលើកអញ្ជលីប្រណម្យបួងសួងគុណបុណ្យព្រះរតនត្រ័យ ព្រមទាំងវត្ថុស័ក្តិសិទ្ធិក្នុងលោក មានទេវតារក្សាព្រះមហាស្វេតច្ឆ័ត្រព្រះបារមីនៃអតីតព្រះមហាក្សត្រ ព្រះមហាក្សត្រីយានី សូមជួយបីបាច់ថែរក្សា **សម្តេចព្រះមហាក្សត្រី** សូមព្រះអង្គសមប្រកបតែនឹងព្រះបរមសុខ ព្រះសុខភាពល្អបរិបូរណ៍ ព្រះជន្មាយុយឺនយូរ ដើម្បីគង់ជាម្លប់ដ៏ត្រជាក់ចំពោះប្រជានុរាស្ត្រ និងប្រទេសជាតិ យូរអង្វែងតទៅ។

ជាសក្ខីភាពនៃកតញ្ញូតាធម៌ ចំពោះព្រះរាជបេសកកម្មមនុស្សធម៌ដោយមិនគិតពីព្រះកាយពល ទូលព្រះបង្គំខ្ញុំម្ចាស់ទាំងអស់គ្នា សូមប្តេជ្ញាជង្វែរតាមព្រះរាជតម្រិះដែលមានសុភនិច្ឆ័យទូលំទូលាយដោយស្មាមីភក្តិ និងភក្តីភាព ដ៏ស្មោះបំផុត។

សេចក្តីគួរពុំគួរ សូម សម្តេចព្រះមហាក្សត្រី ព្រះវររាជមាតាជាតិខ្មែរ ទ្រង់ព្រះមេត្តាប្រោស។

ថ្ងៃ អង្គារ ១៤ រោច ខែជេស្ឋ ឆ្នាំច សំរឹទ្ធិស័ក ព.ស.២៥៦២
រាជធានីភ្នំពេញ ថ្ងៃទី ១២ ខែមិថុនា ឆ្នាំ២០១៨
**តំណាងថ្នាក់ដឹកនាំនិងមន្ត្រីរាជការ**
**នៃក្រសួងមុខងារសាធារណៈ**
**រដ្ឋមន្ត្រី**

**ពេជ្រ ប៊ុនធិន**